## Apologizing



### ការប៉ះទង្គិច

១ តារា៖ អឺយ៉ាស់! សុំទោសបង! មានអីអត់បង?

វុទ្ធី៖ អត់អីទេ។

តារា៖ សុំទោស។ ខ្ញុំប្រញាប់ពេក។

២ តារា៖ អឺយ៉ាស់! ខ្ញុំសុំទោសពូ! មានត្រូវត្រង់ណាអត់ពូ?

ពូ៖ ឯងប្រយ័ត្នប្រយែងតិចមើល។

តារា៖ សុំទោសពូ។ ខ្ញុំអត់បានមើលមិញ។

### ការខកម៉ោងណាត់ជួប

១ ធារីទូរស័ព្ទទៅកញ្ញា៖ សុំទោសកញ្ញា! ខ្ញុំរៀងយឺតបន្តិចហើយ នៅស្ទះចរាចរណ៍។

កញ្ញា៖ អត់អីទេធារី តាមសម្រួល។ ប្រយ័ត្នប្រយែង។

២ ធារី៖ សុំទោសកញ្ញា! ខ្ញុំមកយឺតហើយ! មកចាំយូរនៅ?

កញ្ញា៖ យូរហើយ។ កន្លះម៉ោងហើយ។

| | |
|---|---|
| ការប៉ះទង្គិច | to collide, to hit one another |
| អឺយ៉ាស់ | Oops! |
| មានអីអត់? | Are you alright? / Did anything happen? |
| ប្រញាប់ | to hurry, to be in a hurry |
| ពូ | respectful term of address to older men; uncle |
| មានត្រូវត្រង់ណាអត់? | Are you alright? / Did I hurt you? / Did anything happen? |
| ប្រយ័ត្នប្រយែង | to be careful |
| ... តិចមើល | here: you need to be a bit more [careful] |
| ខកម៉ោង | to be late |
| ទូរស័ព្ទទៅ | to call so. |
| នៅស្ទះចរាចរណ៍ | to be in a traffic jam |
| តាមសម្រួល | Take your time! / No need to rush! |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

## Cultural notes

ប្រពៃណីខ្មែរតម្រូវឲ្យលើកដៃសំពះផងដែរ នៅពេលនិយាយពាក្យសុំទោស គឺដូចគ្នានឹងពេល ជម្រាបសួរ ជម្រាបលា និងអរគុណដែរ។ ប៉ុន្តែ ជាក់ស្តែង
មានតែពេលនិយាយសុំទោសទៅកាន់មនុស្សមានអាយុច្រើនជាងឆ្ងាយ និងមិនសូវជិតស្និទ្ធប៉ុណ្ណោះទេ ដែលគេលើកដៃសំពះ។ ចំពោះមនុស្សស្របាលគ្នា ឬមនុស្សជិតស្និទ្ធ ជាទូទៅមិនមានការលើកដៃសំពះទេ។

| | |
|---|---|
| ប្រពៃណីខ្មែរ | Khmer tradition |
| តម្រូវឲ្យ | to require |
| លើកដៃសំពះ | to raise the hands in a greeting / paying respect gesture |
| ជាក់ស្តែង | in reality, practically |
| អាយុច្រើនជាងឆ្ងាយ | = អាយុច្រើនជាងច្រើន = very much older |
| មិនសូវ ... ប៉ុណ្ណោះទេ | not so ... |
| ជិតស្និទ្ធ | close |
| ស្របាលគ្នា | to be of a similar age |

## Additional dialogue

ធារី៖ រៀងល្ងាចហើយ។ ចាំជួបគ្នាថ្ងៃក្រោយទៀតអីចឹង។
កញ្ញា៖ តស់ទៅអីចឹង។ លើកក្រោយ អត់ឲ្យយឺតដូចថ្ងៃហ្នឹងទៀតទេណា។ ប្រាប់ឲ្យហើយ។
ធារី៖ ដឹងហើយ។ សុំទោសហើយហើយហ្នឹងអា។ មិនយឺតទៀតទេ!

| | |
|---|---|
| រៀងល្ងាចហើយ | it’s late evening already |
| អីចឹង | then, so, therefore |
| តស់ទៅអីចឹង | Ok, then let’s go! |
| អត់ឲ្យយឺតដូច ... ទេណា | don’t be late like [today] |
| ថ្ងៃហ្នឹង = ថ្ងៃនេះ | today |
| ប្រាប់ឲ្យហើយ | I warn you! |
| ដឹងហើយ | I know! / I understand! (equivalent: យល់ហើយ) |
| សុំទោសហើយៗហ្នឹងអា | I’ve already apologized! |
| មិនយឺតទៀតទេ | I won’t be late again |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.